ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គ.ជ.ប

# សេចក្តីណែនាំឱ្យបោះឆ្នោតបាន ឬ ពុំបាន

## បន្ទាប់ពីបានពិនិត្យដោយត្រឹមត្រូវរវាងឯកសារបញ្ជាក់អត្តសញ្ញាណ និងរូបពិតរបស់អ្នកបោះឆ្នោតហើយ

☞ អនុញ្ញាតឱ្យបោះឆ្នោតបាន ៖

១. ឈ្មោះសរសេរត្រូវគ្នា ។

២. បើឈ្មោះសរសេរខុសគ្នា តែសូរដូចគ្នា ។

៣. បើឈ្មោះសរសេរខុសគ្នាដោយខុសអក្ខរាវិរុទ្ធបន្តិចបន្តួច ហើយសូរប្រហែលគ្នា ។

☞ បន្តពិនិត្យថាអាចឱ្យបោះឆ្នោតបាន ឬពុំបាន ៖

១. បើឈ្មោះសរសេរខុសគ្នាដោយខុសអក្ខរាវិរុទ្ធ ដូចជា ខ្វះ ឬលើស ស្រៈ ព្យញ្ជនៈ ជើងអក្សរ វណ្ណយុត្ត នាំឱ្យមានសូរខុសគ្នានោះ ត្រូវបន្តពិនិត្យ ៖

* **ឱ្យបោះឆ្នោតបាន** បើ ភេទ អាយុ អាសយដ្ឋានដូចគ្នា ។
* **ឱ្យបោះឆ្នោតបាន** បើ ទិន្នន័យ ២ ដូចគ្នាក្នុងចំណោមទិន្នន័យទាំង ៣ (ភេទ អាយុ អាសយដ្ឋាន) ។
* **ពុំអនុញ្ញាតឱ្យបោះឆ្នោត** បើ ទិន្នន័យទាំង ៣ (ភេទ អាយុ អាសយដ្ឋាន) ខុសគ្នា ។

២. **បន្តពិនិត្យទិន្នន័យផ្សេងទៀត**ដើម្បីឱ្យប្រាកដថាឈ្មោះណាមួយដែលត្រូវអនុញ្ញាតឱ្យបោះឆ្នោតក្នុងករណីឈ្មោះ ២ ឬច្រើនដូចគ្នា ឬស្រដៀងគ្នា ។

☞ អញ្ជើញទៅជួបប្រធានការិយាល័យបោះឆ្នោត ៖

* បើលេខាធិការរកពុំឃើញឈ្មោះលោកអ្នកក្នុងបញ្ជីបោះឆ្នោត ។
* បើលេខាធិការពុំទទួលស្គាល់ឈ្មោះលោកអ្នកក្នុងបញ្ជីបោះឆ្នោត ឬក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់លោកអ្នក ។

☞ សូមលើកការជំទាស់ទៅប្រធានការិយាល័យបោះឆ្នោត ៖

* បើឃើញលេខាធិការអនុញ្ញាតឱ្យបោះឆ្នោតដោយប្រើ ***"បណ្ណព័ត៌មានអ្នកបោះឆ្នោត"***
* បើឃើញលេខាធិការអនុញ្ញាតឱ្យបោះឆ្នោតដោយប្រើ ***"បណ្ណណាមួយដែលច្បាប់ពុំអនុញ្ញាតឱ្យប្រើ"*** ។